# កិច្ចសន្យាខ្ចីបរិភោគ

មន្ទីរសារការីភ្នំពេញ        ខែតុលា ឆ្នាំ២០១៦        ក្បាលសិទ្ធិគ្រប់យ៉ាង

## អ្វីទៅជាកិច្ចសន្យាខ្ចីបរិភោគ?

**កិច្ចសន្យាខ្ចីបរិភោគ** គឺជាកិច្ចសន្យាដែលអ្នកឱ្យខ្ចីត្រូវប្រគល់ការប្រើប្រាស់ដោយសេរីនូវប្រាក់ ស្បៀងអាហារ ឬវត្ថុជំនួសផ្សេងទៀត ឱ្យទៅអ្នកខ្ចី សម្រាប់អំឡុងពេលមួយ ហើយអ្នកខ្ចីត្រូវសងទៅឱ្យអ្នកឱ្យខ្ចីវិញនូវវត្ថុដែលមានប្រភេទ គុណភាព និង ចំនួន ស្មើគ្នានឹងវត្ថុដែលបានទទួលពីអ្នកឱ្យខ្ចីនោះ។

ពាក្យថាខ្ចីបរិភោគមិនសំដៅដល់ត្រឹមតែការខ្ចីវត្ថុដែលបរិភោគបាននោះឡើយ (នំចំណី ម្ហូបអាហារ) ប៉ុន្តែសំដៅដល់វត្ថុទាំងឡាយណាដែលបាត់បង់ក្រោយពីការប្រើប្រាស់។ ក្នុងន័យនេះ ប្រាក់ដែលអ្នកឱ្យខ្ចីបានឱ្យទៅដល់អ្នកខ្ចី នឹងបាត់បង់ក្រោយពេលឱ្យខ្ចីនោះ ថ្វីត្បិតតែតម្លៃរបស់វានៅតែរក្សាដដែលក៏ដោយ។ ជាក់ស្តែង អ្នកខ្ចីនឹងសងប្រាក់ដែលមានតម្លៃ ៥០០០០៛ ដែលខ្លួនជំពាក់មកអ្នកឱ្យខ្ចីវិញបន្ទាប់ពីរយៈពេលមួយ ប៉ុន្តែប្រាក់នោះនឹងមិនមែនជាក្រដាសប្រាក់ដូចគ្នានឹងអ្វីដែលអ្នកឱ្យខ្ចីបានប្រគល់ឱ្យឡើយ។




ដោយលោកស្រី **មិន្ទស៊ុំ សូលីដា**
សារការីនៃមន្ទីរសារការីភ្នំពេញ


• • •

## មន្ទីរសារការីភ្នំពេញ

មន្ទីរសារការីភ្នំពេញត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ១៣៨ អនក្រ.បក របស់រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី០១-១០-១៥ ដោយមានបេសកកម្មជាអាទិ៍៖

- ទទួលធ្វើកិច្ចសន្យា និងលិខិតគតិយុត្ត
- ផ្តល់យថាភូតភាពលើកិច្ចសន្យា ឬលិខិតគតិយុត្ត ឬឯកសារបកប្រែ
- ចេញសេចក្តីចម្លងយថាភូត
- បញ្ជាក់ធានាហត្ថលេខា និងកាលបរិច្ឆេទនៃកិច្ចសន្យា និងលិខិតគតិយុត្ត
- ផ្តល់ប្រឹក្សាយោបល់ចំពោះកិច្ចការពាណិជ្ជកម្ម វិនិយោគ គ្រួសារ និងការគ្រប់គ្រងចាត់ចែងទ្រព្យសម្បត្តិ
- ទទួលតម្កល់ និងរក្សាទុកច្បាប់ដើមនៃលិខិតគ្រប់ប្រភេទ
- បញ្ជាក់សុពលភាពចំពោះការបង្កើត ឬកែប្រែលក្ខន្តិកៈក្រុមហ៊ុន
- បញ្ជាក់ការចម្លងត្រឹមត្រូវតាមច្បាប់ដើមនូវរាល់លិខិតគតិយុត្ត ឬកិច្ចសន្យា

## តើអ្នកខ្ចីត្រូវបង់នូវតម្លៃតបស្នងណាមួយទៅឱ្យអ្នកឱ្យខ្ចីដែរឬទេ ?

កិច្ចសន្យាខ្ចីបរិភោគអាចធ្វើឡើងដោយយកការប្រាក់ ឬមិនយកការប្រាក់។ ការប្រាក់អាចជាទឹកប្រាក់ ឬវត្ថុផ្សេងទៀត ដែលត្រូវគណនាដោយយកចំនួនទឹកប្រាក់ ឬវត្ថុដែលបានខ្ចី ("ប្រាក់ដើម") មកគុណជាមួយនឹង អត្រាដែលបានកំណត់ ("អត្រាការប្រាក់") តាមសមាមាត្រនឹងអំឡុងពេលដែលបានប្រើប្រាស់ ("រយៈពេលខ្ចី")។ ដើម្បីធ្វើឱ្យការបង់ការប្រាក់ក្លាយទៅជាសិទ្ធិលើបំណុល ជាប្រយោជន៍ដល់អ្នកឱ្យខ្ចី ការព្រមព្រៀងបង្កើតសិទ្ធិលើបំណុលនៃការប្រាក់ត្រូវធ្វើឡើងជាលាយល័ក្ខណ៍អក្សរ និងមានចុះហត្ថលេខាដោយអ្នកខ្ចី។ ជារួម មានន័យថាកិច្ចសន្យាខ្ចីដោយយកការប្រាក់ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរជាដាច់ខាត។

## តើអត្រាការប្រាក់មានចំនួនប៉ុន្មានជាទូទៅ ?

គូភាគីអាចព្រមព្រៀងគ្នាកំណត់អត្រាការប្រាក់បានដោយសេរី ប៉ុន្តែមិនអាចលើសពីអត្រាការប្រាក់អតិបរិមាដែលកំណត់ដោយច្បាប់ ឬបទដ្ឋានគតិយុត្តផ្សេងទៀតឡើយ។ ប្រកាសចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងយុត្តិធម៌ស្តីពីអត្រាការប្រាក់ដែលត្រូវបានកម្រិត កំណត់យកអត្រាការប្រាក់អតិបរិមាត្រឹម **១៨%** ក្នុងមួយឆ្នាំ។

ក្នុងករណីដែលគូភាគីបានត្រឹមកំណត់ថាយកការប្រាក់ ប៉ុន្តែមិនបានកំណត់អត្រាការប្រាក់ជាក់លាក់នោះទេ អត្រាការប្រាក់តាមច្បាប់ **៥%** ត្រូវយកមកអនុវត្ត។

**ការខ្ចីបរិភោគ និងលិខិតសារការី** - នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ត្រង់មាត្រា ៣៥០ ចែងអំពីប្រភេទនៃលិខិតអនុវត្តបានកំណត់ត្រង់ចំណុច "ច" ថា "លិខិតយថាភូតដែលធ្វើដោយសារការី ចំពោះការទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់មានកំណត់ ហើយដែលមានបញ្ជាក់សេចក្តីថ្លែងការណ៍ថា កូនបំណុលនឹងទទួលការអនុវត្តដោយបង្ខំភ្លាមៗ" គឺជាលិខិតអនុវត្តដែលជាមូលដ្ឋាននៃការអនុវត្តដោយបង្ខំ។ ក្នុងន័យនេះ កិច្ចសន្យាខ្ចីបរិភោគធម្មតាដែលពុំត្រូវបានធ្វើឡើងដោយសារការី (ពោលគឺពុំមានហត្ថលេខា និងត្រារបស់សារការីទេ) គឺជាកិច្ចសន្យាឯកជនធម្មតា។ នៅពេលដល់កំណត់សងបំណុល ហើយកូនបំណុលពុំព្រមសង ការទាមទារឱ្យកូនបំណុលសង បើទោះជាបានដាក់ទ្រព្យធានា ឬមានការធានាដោយបុគ្គលផ្សេងពីកូនបំណុលក៏ដោយ ចាំបាច់ត្រូវធ្វើឡើងតាមផ្លូវតុលាការ ដែលត្រូវគិតចាប់ពីនីតិវិធីដាក់ពាក្យប្តឹងរហូតដល់ចប់នីតិវិធីតាមលំដាប់លំដោយនៅតុលាការ ដើម្បីបានសេចក្តីសម្រេចពីអត្ថិភាពនៃសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលសិន មុនពេលអាចយកសេចក្តីសម្រេចនេះទៅធ្វើជាមូលដ្ឋាននៃការអនុវត្តដោយបង្ខំបាន។

ផ្ទុយទៅវិញ បើជាលិខិតយថាភូតរបស់សារការី ផ្អែកតាមមាត្រា ៣៥០ នេះ ម្ចាស់បំណុលគ្រាន់តែដាក់ពាក្យសុំរូបមន្តអនុវត្តពីសារការីដែលធ្វើកិច្ចសន្យាខ្ចីបរិភោគឱ្យនោះ ស្របតាមមាត្រានៃក្រមនីតិវិធីនេះ គឺអាចយកទៅឱ្យតុលាការធ្វើការអនុវត្តដោយបង្ខំ ដើម្បីឱ្យកូនបំណុលសងប្រាក់បានភ្លាមៗ។ ដូច្នេះ ករណីចុងក្រោយនេះ ពិតជាអាចចំណេញទាំងពេលវេលា និងមានសុវត្ថិភាពផ្លូវច្បាប់ដល់ម្ចាស់បំណុលយ៉ាងប្រាកដ។